00658634

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

E72

## អង្គជំនុំជម្រះសាលាដំបូង

**ជូនចំពោះ:** ភាគីទាំងអស់នៃសំណុំរឿង០០២ កាលបរិច្ឆេទ: ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង, មន្ត្រីជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង, ផ្នែកគ្រប់គ្រងសវនាការ

**កម្មវត្ថុ:** វិសោធនកម្មនៃលក្ខខណ្ឌតម្រូវឱ្យភ្ជាប់សម្ភារៈដែលមានក្នុងបញ្ជីតារាងមូលដ្ឋានសំអាងផ្លូវច្បាប់ ដែលមានជាសាធារណៈរួចហើយ និងអាចរកបានពីភាគីទាំងអស់

អង្គជំនុំជម្រះសាលាដំបូងសូមយោងទៅលើសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខអ.វ.ត.ក (អ.វ.ត.ក/២០០៧/០១/វិ.០៦) ប្រការ ៦.៣ ដែលតាមរយៈនេះ "ឯកសារត្រូវដាក់ជាមួយសេចក្តីចំលងនៃបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ដែលប្រើប្រាស់ជាឯកសារយោង លើកលែងតែឯកសារយោងមាននៅក្នុងកំរងអត្ថបទច្បាប់របស់អ.វ.ត.ក មានផ្សាយនៅក្នុងគេហទំព័ររបស់ អ.វ.ត.ក"។

អង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគីទាំងអស់ថា អង្គជំនុំជម្រះនឹងអនុញ្ញាតឱ្យភាគីទាំងអស់ដោយមិនចាំបាច់ចម្លងជូននូវឯកសារ ដូចជា ករណីយុត្តិសាស្ត្ររបស់តុលាការ *មិនអចិន្ត្រៃយ៍* និងអត្ថបទនានានៃលិខិតូបករណ៍អន្តរជាតិល្បីៗ ដែលមានរួចហើយជាសាធារណៈ ហើយអាចចូលទទួលយកបានយ៉ាងងាយស្រួលដោយអង្គជំនុំជម្រះ និងគ្រប់ភាគីទាំងអស់។ ទោះបីជាយ៉ាងណា ឯកសារទាំងនេះគួរតែត្រូវ ដាក់ក្នុងបញ្ជីតារាងមូលដ្ឋានសំអាងផ្លូវច្បាប់ ដើម្បីមានភាពងាយស្រួលក្នុងការយោងទៅរក។

ទោះជាយ៉ាងណាក៏ដោយ ឯកសារយោងសំអាងផ្លូវច្បាប់នានា ដែលពិបាកនឹងរកបានដោយងាយស្រួល នោះគួរតែត្រូវបានដាក់ជាបញ្ជីឯកសារនៅក្នុងតារាងមូលដ្ឋានសំអាងផ្លូវច្បាប់ស្របតាមសេចក្តីណែនាំអនុវត្តដែលបានលើកឡើងខាងលើ។

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 05 / 04 / 2011
ម៉ោង (Time/Heure): 11:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA